## បទរំលោភសេពសន្ថវៈ (rape)

ក្នុងច្បាប់អន្តរជាតិ (international law) មិនទាន់មាននិយមន័យច្បាស់អំពីអ្វីទៅជាការ រំលោភសេពសន្ថវៈ។ បទនេះ ត្រូវបានហាមឃាត់តាំងពីក្នុង Lieber Code of 1863 តែមិនមានចែងក្នុងអនុសញ្ញា Hague ឆ្នាំ១៩០៧ ទេ។ វាទើបត្រូវបានចែងក្នុងអនុសញ្ញាហ្សឺណែវ GCs ទាំងបួនក្នុងមាត្រា២៧។

តាមយុត្តិសាស្ត្រ បទនេះមានធាតុផ្សំ៖ ១. ការដាក់បញ្ចូលអង្គជាត ឬវត្ថុ ទោះបីរាក់ ឬជ្រៅ (ទៅក្នុងអង្គជាត ឬរន្ធគូថ ឬមាត់នៃជនរងគ្រោះ)។ ២. ទង្វើនោះ មិនមានការយល់ព្រមពីជនរងគ្រោះ និងទី៣. អ្នកប្រព្រឹត្តមានចេតនាដាក់បញ្ចូល ទោះដឹងថា វាកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះក្តី។ ការព្រមព្រៀងនេះ សំដៅលើការព្រមដោយស្ម័គ្រចិត្ត (Delalic, IT-96-21-T, 1998)។

សម្រាប់ ICC បទនេះមានចែងក្នុងធាតុផ្សំនៃបទល្មើស (elements of crimes)។ មានការសន្មតថា ក្នុងពេលមានសង្គ្រាម បទរំលោភ ដែលជាបទឧក្រិដ្ឋកម្មសង្គ្រាម (war crime) ឬ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity) កើតមានឡើងក្នុងស្ថានភាពបង្ខំ (គ្មានការព្រមព្រៀង)។

ការគម្រាម ឬហិង្សា មិនតម្រូវឲ្យមានទេ។ ក្នុងន័យនេះហើយ ទើបយុត្តិសាស្ត្រខ្លះ មិនទទួលយកនូវការព្រមព្រៀងជាការដោះសារទេ (consent)។

បទរំលោភសេពសន្ថវៈ ជាការបំពានធ្ងន់ធ្ងរនៃវិធានមនុស្សធម៌ (international humanitarian law) និងជាវិធានច្បាប់ទំនៀមទម្លាប់អន្តរជាតិ (international customary international) និងបានក្លាយជាបទល្មើសដោយឡែកតែឯង (stand-alone crime)។ រំលោភសេពសន្ថវៈ បង្កនូវការឈឺចាប់ធ្ងន់ធ្ងរ ដែលអាចត្រូវបានចាត់ថា ជាអំពើទារុណកម្ម (torture)។ ជាចុងក្រោយ បទរំលោភ មិនទាមទារនូវមូលហេតុនៃការប្រព្រឹត្ត (motive) ដោយសារ វាអាចត្រូវចាត់ថាជាបទធ្វើទុក្ខបុកម្នេញ (persecution) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, p. 477)។